**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៦២..អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ (ប.ជ.រ.ព.ក)

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៤ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៦/០០៤ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃពិធីសារស្តីពីការទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្មការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារដែលបំពេញបន្ថែមលើអនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីការប្រឆាំងបទឧក្រិដ្ឋឆ្លងដែនដែលមានអង្គការចាត់តាំង
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

# សម្រេច

**មាត្រា ១.-** ត្រូវបានបង្កើតគណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ហៅកាត់ថា "ប.ជ.រ.ព.ភ" ។

**មាត្រា ២.-** គណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរមនុស្ស ការរត់ពន្ធការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ ប.ជ.រ.ព.ភ មានសមាសភាព ដូចតទៅ :

១-រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន

២-រដ្ឋមន្ត្រីក្រសួងកិច្ចការនារី អនុប្រធាន

៣-រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អនុប្រធាន

៤-រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អនុប្រធាន

៥-រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អនុប្រធាន

៦-រដ្ឋមន្ត្រីក្រសួងទេសចរណ៍ សមាជិក

៧-រដ្ឋមន្ត្រីក្រសួងសុខាភិបាល សមាជិក

៨-រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា សមាជិក

៩-រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ០១រូប សមាជិក

១០-រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ០១រូប (ទទួលបន្ទុកជាប្រធានលេខាធិការដ្ឋាន) សមាជិកអចិន្ត្រៃយ៍

១១-រដ្ឋលេខាធិការក្រសួងការពារជាតិ ០១រូប សមាជិក

១២-រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ០១រូប សមាជិក

១៣-រដ្ឋលេខាធិការក្រសួងព័ត៌មាន ០១រូប សមាជិក

១៤-រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១រូប សមាជិក

១៥-រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ០១រូប សមាជិក

១៦-រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ០១រូប សមាជិក

១៧-អគ្គស្នងការ នគរបាលជាតិ សមាជិក

១៨-មេបញ្ជាការ កងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក។

មាត្រា ៣.- គណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ គឺជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងកិច្ចការប្រយុទ្ធប្រឆាំងអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស ការធ្វើ អាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ និងមានភារកិច្ចដូចខាងក្រោម :

- ដឹកនាំសម្របសម្រួលជាមួយក្រសួង ស្ថាប័នដៃគូ និងបណ្តាប្រទេសពាក់ព័ន្ធ សំដៅការពារប្រជាពលរដ្ឋ ជាពិសេសស្ត្រី និងកុមារ ឱ្យរួចផុតពីអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្ម និងអាជីវកម្មផ្លូវភេទ
- ជាបញ្ជាការផ្ទាល់លើលេខាធិការដ្ឋានក្នុងការត្រួតពិនិត្យ វាយតម្លៃសភាពការណ៍ការអនុវត្តន៍ផែនការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ របស់ក្រុមការងារបច្ចេកទេសទាំង ០៦ (ប្រាំមួយ) គណៈបញ្ជាការឯកភាពរាជធានី និងខេត្តទាំងអស់
- ពិនិត្យ សម្រេចលើរបាយការណ៍ដែលបានដាក់ជូនដោយលេខាធិការដ្ឋាន ដើម្បីដាក់ជូនរាជរដ្ឋាភិបាល
- ពិនិត្យ ដោះស្រាយសំណូមពរ និងអនុសាសន៍នានា ផ្តល់មតិណែនាំ ដឹកនាំ ដើម្បីឱ្យលេខាធិការដ្ឋាន និងក្រុមការងារបច្ចេកទេសទាំងអស់អនុវត្ត និងចាត់វិធានការទៅតាមមុខសញ្ញារៀងៗខ្លួន
- ណែនាំ និងជំរុញគណៈបញ្ជាការឯកភាពរាជធានី-ខេត្ត អាជ្ញាធរមានសមត្ថកិច្ចក្រសួង ស្ថាប័នពាក់ព័ន្ធ ឱ្យពង្រឹងការយកចិត្តទុកដាក់ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ
- ដាក់វិធានការដើម្បីជួយសង្គ្រោះ ការពារ លើកកម្ពស់គុណភាពសេវានៃការងារស្តារនីតិសម្បទា ធ្វើសមាហរណកម្ម និងមាតុភូមិនិវត្តន៍ជនរងគ្រោះ ជាពិសេសស្ត្រី និងកុមារឱ្យបានល្អប្រសើរ

- លុបបំបាត់និទណ្ឌភាព ដោយជំរុញឱ្យមានការស៊ើបអង្កេត ការផ្តន្ទាទោសមេក្លោង និង ជនល្មើសពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ
- ជំរុញផ្សព្វផ្សាយដើម្បីបង្កើនការជឿទុកចិត្តពីប្រជាពលរដ្ឋ ជាពិសេសពីជនរងគ្រោះលើសេវាសាធារណៈ និងដើម្បីបង្កើនការចូលរួមអនុវត្តច្បាប់
- ទទួលខុសត្រូវដឹកនាំសម្របសម្រួលក្រុមការងារដែលពាក់ព័ន្ធ និងជាអ្នកជំរុញសកម្មភាពក្នុងសាមីក្រសួង ក្នុងការអនុវត្តន៍ផែនការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ព្រមទាំងធ្វើរបាយការណ៍ឱ្យបានទៀងទាត់ផ្ញើមកលេខាធិការដ្ឋាន
- គណៈកម្មាធិការជាតិដឹកនាំ ជួបប្រជុំគ្នាទៀងរាល់ត្រីមាស ដើម្បីផ្លាស់ប្តូរយោបល់លើរបាយការណ៍ដែលរៀបចំដោយលេខាធិការដ្ឋាន ដោះស្រាយសំណូមពរ ពិនិត្យអនុសាសន៍ទាំងឡាយដែលបានស្នើឡើង វាយតម្លៃសភាពការណ៍ កំណត់ទិសដៅ និងយុទ្ធសាស្ត្របន្ត
- ក្នុងករណីចាំបាច់ ប្រធានអាចកោះអញ្ជើញសមាជិកជួបប្រជុំវិសាមញ្ញបាន ។ ក្នុងកិច្ចប្រជុំនីមួយៗ បើសមាជិកណាម្នាក់ជាប់រវល់ អាចចាត់តាំងតំណាងជាមន្ត្រីជាន់ខ្ពស់ដែលមានសិទ្ធិសម្រេចឱ្យមកចូលរួមប្រជុំជំនួសបាន
- ធ្វើរបាយការណ៍ទៀងទាត់ជូនប្រមុខរាជរដ្ឋាភិបាល អំពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ
- គណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ មានសិទ្ធិប្រើប្រាស់រូបសញ្ញា និងត្រាដោយ ឡែករបស់គណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ ។

**មាត្រា ៤.**– គណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ មានលេខាធិការដ្ឋានមួយ ដែលមាននាយកដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន នៃក្រសួងមហាផ្ទៃ ជាសេនាធិការ អមដោយក្រុមការងារបច្ចេកទេសចម្រុះស្ថាប័ន ចំនួន០៦ (ប្រាំមួយ) និង

គណៈកម្មាធិការ ប.ជ.រ.ព.ភ ថ្នាក់រាជធានី និងខេត្តទាំងអស់ដែលមានភារកិច្ច ធ្វើឱ្យសម្រេចនូវផែនការប្រយុទ្ធប្រឆាំង នឹងអំពើ ជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្ម លើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារនៅព្រះរាជាណាចក្រកម្ពុជា ។ លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ ដឹកនាំដោយប្រធានមួយរូប ជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ អមដោយអនុប្រធានមួយចំនួនតាមការចាំបាច់ ។ ប្រធានក្រុមការងារបច្ចេកទេសទាំងប្រាំមួយ គឺជាសមាជិកលេខាធិការដ្ឋាន ។

លេខាធិការដ្ឋាននេះ មានសិទ្ធិប្រើប្រាស់មន្ត្រីជំនាញក្នុងស្ថាប័នសាមី និងអាចស្នើសុំជួលអ្នកជំនាញការផ្នែកបច្ចេកទេស តាមការចាំបាច់ ដើម្បីជាជំនួយក្នុងការរៀបចំផែនការ ការពង្រឹងសមត្ថភាពក្រុមការងារ ការបង្កើតសម្ភារៈសម្រាប់ផ្សព្វផ្សាយ ការបណ្តុះបណ្តាល ការត្រួតពិនិត្យការវាយតម្លៃ ការប្រមូលរបាយការណ៍បូកសរុប និងការចងក្រងឯកសារជាដើម ។

មាត្រា ៥.- លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិ ដែលជាកញ្ចប់ថវិកាដោយឡែកនៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងមហាផ្ទៃ

លេខាធិការដ្ឋាននេះមានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិ ដែលបានមកពីប្រភពហិរញ្ញប្បទាន សហប្រតិបត្តិការអន្តរជាតិ និងពីប្រភពផ្សេងៗទៀត សម្រាប់បំពេញការងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព។

មាត្រា ៦.- ក្រុមការងារទាំងប្រាំមួយ មានសមាសភាពជាអន្តរក្រសួង និងមានតំណាងអង្គការសង្គមស៊ីវិល ដែលធ្វើការពាក់ព័ន្ធតាមជំនាញចូលរួម ។ ក្រុមការងារទាំងប្រាំមួយគឺ :

១. ក្រុមការងារទប់ស្កាត់

២. ក្រុមការងារការពារ ស្តារនីតិសម្បទា សមាហរណកម្ម និងមាតុភូមិនិវត្តន៍

៣. ក្រុមការងារអនុវត្តច្បាប់

៤. ក្រុមការងារកិច្ចការយុត្តិធម៌

៥. ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ

៦. ក្រុមការងារកិច្ចការកុមារ ។

មាត្រា ៧.- គណៈកម្មាធិការរាជធានី-ខេត្ត ប.ជ.រ.ព.ភ មានរចនាសម្ព័ន្ធកំណត់ដោយគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ ដែលត្រូវដឹកនាំដោយអភិបាលរាជធានី-ខេត្ត និងមានលេខាធិការដ្ឋានមួយ មានទីតាំងស្ថិតក្នុងសាលារាជធានី-ខេត្ត អមដោយក្រុមការងារអន្តរមន្ទីរ ដែលទទួលបន្ទុកអនុវត្តភារកិច្ចពាក់ព័ន្ធជំនាញទាំងប្រាំមួយ ។

មាត្រា ៨.- គណៈកម្មាធិការ រាជធានី-ខេត្ត ប.ជ.រ.ព.ភ

មានភារកិច្ចអនុវត្តគោលនយោបាយ រាជរដ្ឋាភិបាលប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើពាក់ព័ន្ធដទៃទៀតនៅក្នុងដែនដី របស់ខ្លួន ព្រមទាំងអនុវត្តគោលការណ៍ និងបទបញ្ជាផ្សេងៗពីគណៈកម្មាធិការជាតិដឹក- នាំប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈលេខាធិការដ្ឋានគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ ។

មាត្រា ៩.- ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមការងារទាំងប្រាំមួយ និងគណៈកម្មាធិការដឹកនាំ ប.ជ.រ.ព.ភ រាជធានី-ខេត្ត នឹងកំណត់ដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និង ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការរាជធានី-ខេត្ត ប.ជ.រ.ព.ភ នឹងកំណត់ដោយប្រកាស របស់ប្រធានគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ ។

មាត្រា ១០.- បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១១.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អភិបាលរាជធានី អភិបាលគ្រប់ខេត្ត និង សមាសភាពដូចមានចែងក្នុងមាត្រា ២ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ឱ្យមាន ប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីចុះហត្ថលេខា ។

ភ្នំពេញ ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ ២០០៩

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២ និងមាត្រា ១១*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*